**អង្គការសហប្រជាជាតិ**

**ក្រុមប្រឹក្សា សេដ្ឋកិច្ច និងសង្គមកិច្ច**

**សំរាប់ការចែកចាយទូទៅ**
**ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០២**
**អត្ថបទដើម : អង់គ្លេស**

**ខ្លឹមសារនៃកិច្ចប្រជុំឆ្នាំ ២០០២**
ញ៉ូយក ថ្ងៃទី ០១ ដល់ថ្ងៃទី ២៦ កក្កដា ២០០២
ចំណុចទី១៤( ខ ) នៃរបៀបវារៈបណ្តោះអាសន្ន [១]
**បញ្ហាសង្គម និងសិទ្ធិមនុស្ស : សិទ្ធិមនុស្ស**

# អនុសាសន៍ជាគោលការណ៍ទូទៅ និងជាគោលការណ៍ណែនាំ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស

## របាយការណ៍របស់ឧត្តមស្នងការអង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្ស ដាក់ជូនក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច

**ខ្លឹមសារ**


| | កថាខ័ណ្ឌ | ទំព័រ |
|---|---|---|
| អនុសាសន៍ជាគោលការណ៍ទូទៅស្តីពី សិទ្ធិមនុស្ស និងការជួញដូរមនុស្ស | ១-១៧ | ៣ |
| ការគិតជាបឋមអំពីសិទ្ធិមនុស្ស | ១-៣ | ៣ |
| ការទប់ស្កាត់ការជួញដូរមនុស្ស | ៤-៦ | ៣ |
| ការការពារ និងកិច្ចគាំពារ | ៧-១១ | ៤ |
| ការចាត់ទុកជាបទព្រហ្មទណ្ឌ-ការផ្តន្ទាទោស និងការទទួលបានភាពជាសះស្បើយ | ១២-១៧ | ៥ |
| អនុសាសន៍ជាគោលការណ៍ណែនាំ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស | | ៦ |


---

១. E/2002/100

ឯកសារត្រូវបានដាក់ជូនទៅសេវាកម្មមហាសន្និបាតយឺត ដោយពុំតំរូវឱ្យមានការពន្យល់ណាមួយនៅក្រោមកថាខណ្ឌទី៨ សេចក្តីសំរេចរួមរបស់មហាសន្និបាតលេខ ៥៣/២០៨ B ទេ ដោយហេតុនេះហើយ មហាសន្និបាតបានសំរេចថា ប្រសិនបើរបាយការណ៍ត្រូវបានដាក់ជូនយឺត ត្រូវមានចុះមូលហេតុនៅរឹមទំព័រខាងក្រោម ។

02.40168(E) 200602
*0240168*

គោលការណ៍ណែនាំទី១ : ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ៦

គោលការណ៍ណែនាំទី២ : ការកំណត់អត្តសញ្ញាណជនដែលត្រូវជួញដូរ និងជនល្មើសជួញដូរមនុស្ស ៧

គោលការណ៍ណែនាំទី៣ : ការស្រាវជ្រាវ វិភាគ និងវាយតំលៃ និងផ្សព្វផ្សាយព័តមាន ៩

គោលការណ៍ណែនាំទី៤ : ការធានាឱ្យមានក្របខណ្ឌអនុវត្តច្បាប់គ្រប់គ្រាន់ ១១

គោលការណ៍ណែនាំទី៥ : ការធានាឱ្យមានការឆ្លើយតបគ្រប់គ្រាន់ពីស្ថាប័នអនុវត្តច្បាប់ ១៣

គោលការណ៍ណែនាំទី៦ : កិច្ចការពារ និងគាំទ្រដល់អ្នកដែលត្រូវគេជួញដូរ ១៥

គោលការណ៍ណែនាំទី៧ : ការទប់ស្កាត់ការជួញដូរមនុស្ស ១៦

គោលការណ៍ណែនាំទី៨ : ការចាត់វិធានការពិសេសសំរាប់ការការពារ និងគាំពារកុមាររងគ្រោះ ដោយសារអំពើជួញដូរមនុស្ស ១៨

គោលការណ៍ណែនាំទី៩ : ការទទួលបានដំណោះស្រាយ ២០

គោលការណ៍ណែនាំទី១០ : កាតព្វកិច្ចរបស់កងកំលាំងរក្សាសន្តិភាព នគរបាល មន្ត្រីបំរើការងារមនុស្សធម៌ និងការទូត ២១

គោលការណ៍ណែនាំទី១១ : កិច្ចសហការ និងការសំរបសំរួល រវាងរដ្ឋ និងរដ្ឋនានានៅក្នុងតំបន់ ២២

# អនុសាសន៍ជាគោលការណ៍ទូទៅ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស [២]

**<u>ការគិតជាបឋមអំពីសិទ្ធិមនុស្ស</u> :**

១. សិទ្ធិមនុស្សរបស់ជនដែលត្រូវបានគេជួញដូរ គឺជាចំណុចសំខាន់នៃរាល់កិច្ចខិតខំប្រឹងប្រែងដើម្បីបង្ការ និងប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ព្រមទាំងដើម្បីការពារ និងផ្តល់ការគាំពារ និងការរកយុត្តិធម៌ឱ្យដល់ជនរងគ្រោះ ។

២. យោងតាមច្បាប់អន្តរជាតិ រដ្ឋទាំងឡាយត្រូវទទួលខុសត្រូវ ដោយអនុវត្តឱ្យបានហ្មត់ចត់ក្នុងការទប់ស្កាត់ ការស៊ើបអង្កេត ការចោទប្រកាន់លើជនជួញដូរមនុស្ស និងផ្តល់កិច្ចគាំពារ និងកិច្ចការពារដល់ជនដែលត្រូវគេជួញដូរ ។

៣. វិធានការប្រឆាំងអំពើជួញដូរមនុស្ស មិនត្រូវមានផលប៉ះពាល់ដល់សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សឡើយ ជាពិសេស សិទ្ធិរបស់ជនដែលត្រូវគេជួញដូរ ជនអន្តោប្រវេសន្ត ជនផ្លាស់ប្តូរទីលំនៅនៅក្នុងប្រទេស ជនភាសខ្លួន និងជនសុំសិទ្ធិជ្រកកោននយោបាយ ។

**<u>ការទប់ស្កាត់អំពើជួញដូរមនុស្ស</u>**

៤. យុទ្ធសាស្ត្រទាំងឡាយដែលមានគោលដៅទប់ស្កាត់ការជួញដូរមនុស្ស ត្រូវតែឆ្លើយតបទៅនឹងបុព្វហេតុ ឬមូលហេតុនៃការជួញដូរមនុស្ស ។

---

២. ពាក្យ " ការជួញដូរមនុស្ស" ដែលប្រើនៅក្នុងគោលការណ៍ទូទៅ និងគោលការណ៍ណែនាំនេះ មានន័យថា ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬការប្រើកំលាំង ឬការបង្ខិតបង្ខំតាមរូបភាព ផ្សេងៗ ដូចជាការចាប់ពង្រត់ ការក្លែងបន្លំ ការបោកបញ្ឆោត ការរំលោភលើអំណាច ឬតួនាទីទៅលើជនដែលងាយទទួលរងគ្រោះ ឬការផ្តល់ ឬការទទួលជាលុយកាក់ ឬផលកំរៃផ្សេងៗដើម្បីអោយមានការយល់ព្រមពីអ្នកគ្រប់គ្រងលើជនម្នាក់ទៀត ក្នុងគោលបំណងដើម្បីកេងប្រវ័ញ្ច។ ការកេងប្រវ័ញ្ចត្រូវរាប់បញ្ចូលជា អប្បបរិមានូវការធ្វើអាជីវកម្មពេស្យាចារលើអ្នកដទៃ ឬការធ្វើអាជីវកម្មផ្លូវភេទតាមរូបភាពផ្សេងទៀត ការងារដោយបង្ខំ ឬសេវាកម្មទាសភាព ឬការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងទាសភាព ភាពជាអ្នកបំរើដាច់ថ្លៃ ឬ ការលក់ដូរសរីរាង្គជាដើម ។ ប្រភពឯកសារ: ពិធីសារស្តីពីការទប់ស្កាត់ ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូរមនុស្សជាពិសេសស្ត្រី និង កុមារបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ( មាត្រា ៣ ( ក) ។

៥. រដ្ឋទាំងឡាយ និងអង្គការទាំងឡាយដែលនៅក្នុងប្រទេសនោះ ត្រូវតែធានាថា រាល់ការអន្តរាគមន៍របស់ខ្លួន ត្រូវដោះស្រាយទៅលើកត្តាទាំងឡាយដែលបណ្តាលឱ្យមានការកើនឡើងនៃអំពើជួញដូរមនុស្ស រួមមាន ភាពមិនស្មើភាពគ្នា ក្នុងសង្គម ភាពក្រីក្រ និងរាល់ទំរង់នៃការរើសអើង ។

៦. រដ្ឋត្រូវអនុវត្តឱ្យបានហ្មត់ចត់ ក្នុងការកឱ្យឃើញ និងលុបបំបាត់ចោលនូវការពាក់ព័ន្ធ ឬការសមគំនិតរបស់ស្ថាប័នសាធារណៈ ក្នុងសកម្មភាពជួញដូរមនុស្ស ។ មន្ត្រីសាធារណៈទាំងឡាយណាដែលសង្ស័យថាមានការពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ត្រូវតែធ្វើការស៊ើបអង្កេត និងផ្តន្ទាទោសឱ្យបានសមស្រប ប្រសិនបើពួកគេរកឃើញថាមានទោស ។

## កិច្ចការពារ និងកិច្ចគាំពារ

៧. ជនដែលត្រូវគេជួញដូរ មិនត្រូវបាន ឃុំឃាំង ចោទប្រកាន់ ឬផ្តន្ទាទោសពីបទអន្តោប្រវេសន្តខុសច្បាប់ នៅក្នុងប្រទេសដែលជនរងគ្រោះដោយសារការជួញដូរ បានឆ្លងកាត់ ឬស្នាក់នៅ ឬពីបទពាក់ព័ន្ធក្នុងសកម្មភាពខុសច្បាប់ ដែលការពាក់ព័ន្ធនោះ គឺជាលទ្ធផលដោយផ្ទាល់នៃស្ថានភាពរបស់ជនដែលត្រូវគេជួញដូរ ។

៨. រដ្ឋត្រូវធានាថា ជនដែលត្រូវគេជួញដូរ ត្រូវការពារកុំមានការកេងប្រវ័ញ្ច ឬទទួលរងគ្រោះថ្នាក់បន្តទៀត និងត្រូវធានាឱ្យជនរងគ្រោះ ទទួលបានសេវាព្យាបាលគ្រប់គ្រាន់ដល់សុខភាពរាងកាយ និងផ្លូវចិត្ត ។ កិច្ចគាំទ្រផ្តល់ជំនួយខាងលើនេះ មិនត្រូវធ្វើឡើងដោយមានលក្ខ័ណ្ឌ ឬផ្អែកលើសមត្ថភាព ឬឆន្ទះរបស់ជនរងគ្រោះចូលរួមសហការក្នុងដំណើរការរឿងក្តី តាមផ្លូវច្បាប់ឡើយ ។

៩. ជំនួយខាងផ្នែកច្បាប់ និងផ្នែកផ្សេងៗទៀតដល់ជនរងគ្រោះ ត្រូវផ្តល់ដល់ជនរងគ្រោះក្នុងអំឡុងពេលដំណើរនីតិវិធីព្រហ្មទណ្ឌ និងរដ្ឋប្បវេណីប្រឆាំងនឹងជនសង្ស័យជួញដូរមនុស្ស ។ រដ្ឋត្រូវផ្តល់កិច្ចការពារ និងកន្លែងស្នាក់នៅបណ្តោះអាសន្នដល់ជនរងគ្រោះ និងសាក្សី ក្នុងដំណើរការនីតិវិធីច្បាប់ ។

១០. កុមារដែលរងគ្រោះដោយសារអំពើជួញដូរមនុស្ស ត្រូវចាត់ទុកជាកុមាររងគ្រោះ ។ ផលប្រយោជន៍ចំបងរបស់កុមារ ត្រូវយកចិត្តទុកដាក់បំផុត គ្រប់ពេលវេលាទាំងអស់ ។ ជនរងគ្រោះជាកុមារត្រូវទទួលបាននូវកិច្ចគាំពារ និងកិច្ចការពារសមស្រប ។ កុមារត្រូវទទួលបាននូវការយកចិត្តទុកបំផុតចំពោះភាពងាយរងគ្រោះថ្នាក់ សិទ្ធិ និងសេចក្តីត្រូវការរបស់កុមារ ។

១១. សុវត្ថិភាពក្នុងការធ្វើមាតុភូមិនិវត្តន៍នៃអំពើជួញដូរមនុស្ស (បើសិនអាចមាន) របស់ជនដែលត្រូវបានគេជួញដូរ ត្រូវធានាដោយរដ្ឋដែលជនរងគ្រោះកំពុងវត្តមាន និងរដ្ឋដើមរបស់ជនរងគ្រោះ ។ ជនដែលត្រូវគេជួញដូរ ត្រូវទទួលបានដំណោះស្រាយស្របច្បាប់ផ្សេងៗ ក្នុងការធ្វើមាតុភូមិនិវត្តន៍ នៅក្នុងករណីដែលមានហេតុផលថា ការធ្វើមាតុភូមិនិវត្តនោះ អាចប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុវត្ថិភាព ដល់ជនដែលត្រូវគេជួញដូរ ឬគ្រួសាររបស់គេ ។

**ការចាត់ទុកជាបទព្រហ្មទណ្ឌ ការផ្តន្ទាទោស និងការទទួលបានភាពជាសះស្បើយ**

១២. រដ្ឋត្រូវអនុម័តបទបញ្ញត្តិសមស្រប និងរៀបចំឱ្យមានវិធានការផ្សេងៗទៀត ដើម្បីឱ្យអំពើទាំងនេះ គឺជាបទល្មើសព្រហ្មទណ្ឌ អំពើជួញដូរមនុស្ស ធាតុផ្សំនៃអំពើ [៣] និងអំពើពាក់ព័ន្ធដទៃទៀត [៤]។

១៣. រដ្ឋត្រូវ ស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោស ប្រកបដោយប្រសិទ្ធិភាពខ្ពស់ ក្នុងរឿងក្តីជួញដូរមនុស្ស រួមទាំងធាតុផ្សំនៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធដទៃទៀត ទោះបីអំពើទាំងនោះបានប្រព្រឹត្តឡើងដោយមន្ត្រីរដ្ឋាភិបាល ឬ មិនមែនរដ្ឋាភិបាល ។

១៤. រដ្ឋត្រូវធានាថា បទល្មើសជួញដូរមនុស្ស ធាតុផ្សំនៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធដទៃទៀត ត្រូវតែជាបទល្មើសដែលអាចធ្វើបត្យាប័ន យោងតាមច្បាប់ជាតិ និងសន្ធិសញ្ញាស្តីពីបត្យាប័ន ។ រដ្ឋនានាត្រូវសហការដើម្បីធានាឱ្យមាននីតិវិធីបត្យាប័នសមស្រប ឱ្យស្របទៅនឹងច្បាប់អន្តរជាតិ ។

១៥. រដ្ឋត្រូវធានាឱ្យមានការផ្តន្ទាទោស ប្រកបដោយប្រសិទ្ធិភាព និងសមស្រប ទៅលើរូបវន្តបុគ្គល និងនីតិបុគ្គលដែលត្រូវបានរកឃើញថាមានទោសពីបទជួញដូរមនុស្ស ឬ ធាតុផ្សំនៃអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធដទៃទៀត ។

១៦. នៅក្នុងករណីសមស្រប រដ្ឋត្រូវរឹបអូសទ្រព្យសម្បត្តិរបស់រូបវន្តបុគ្គល ឬ នីតិបុគ្គល ដែលមានការពាក់ព័ន្ធនៅក្នុងរឿងក្តីជួញដូរមនុស្ស ។ តាមដែលអាចធ្វើទៅបាន ទ្រព្យសម្បត្តិដែលរឹបអូសនោះ ត្រូវយកទៅប្រើប្រាស់ដើម្បីជួយទំនុកបំរុង និងសងជំងឺចិត្តដល់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ។

១៧. រដ្ឋត្រូវធានាថា អ្នកដែលត្រូវគេជួញដូរ ត្រូវទទួលបាននូវដំណោះស្រាយនិងការសងជំងឺចិត្តសមស្របតាមច្បាប់ ។

---

៣. នៅក្នុងកម្មវត្ថុនៃគោលការទូទៅ និងគោលការណែនាំនេះ "ធាតុផ្សំនៃអំពើ" និង "ធាតុផ្សំនៃបទល្មើស" រួមមាន ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬការប្រើកំលាំង ឬការបង្ខិតបង្ខំតាមរូបភាពផ្សេងៗ ដូចជាការចាប់ពង្រត់ ការក្លែងបន្លំ ការបោកបញ្ឆោត ការរំលោភលើអំណាច ឬតួនាទីទៅលើជនដែលងាយទទួលរងគ្រោះ ឬការផ្តល់ ឬការទទួលជាលុយកាក់ ឬផលកំរៃផ្សេងៗដើម្បីអោយមានការយល់ព្រមពីអ្នកគ្រប់គ្រងលើជនម្នាក់ទៀត ក្នុងគោលបំណងដើម្បីធ្វើអាជីវកម្ម។ ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកអ្នកណាម្នាក់ក្រោមអាយុ ១៨ឆ្នាំ គឺបានប្រព្រឹត្តិនូវធាតុផ្សំនៃអំពើ និងធាតុផ្សំនៃបទល្មើសជួញដូរកុមារ។ ប្រភពឯកសារៈ ពិធីសារស្តីពីការទប់ស្កាត់ ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូរមនុស្សជាពិសេសស្រ្តី និង កុមារបន្ថែមលើ អនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ( មាត្រា ៣ ( ក) និង( គ) ។

៤. នៅក្នុងកម្មវត្ថុនៃគោលការទូទៅ និងគោលការណែនាំនេះ "អំពើពាក់ព័ន្ធ" នឹងបទល្មើសជួញដូរមនុស្ស គឺរួមមាន ការធ្វើអាជីវកម្មពេស្យាចារលើអ្នកដទៃ ឬការធ្វើអាជីវកម្មផ្លូវភេទតាមរូបភាពផ្សេងទៀត ការងារដោយបង្ខំ ឬសេវាកម្មទាសភាព ឬការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងទាសភាព ភាពជាអ្នកបំរើដាច់ថ្លៃ ឬការលក់ដូរសេរីរាង្គជាដើម ។ ប្រភពឯកសារៈ ពិធីសារស្តីពីការទប់ស្កាត់ ការបង្ក្រាប និង ការផ្តន្ទាទោសការជួញដូរមនុស្សជាពិសេសស្រ្តី និង កុមារបន្ថែមលើ អនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ( មាត្រា ៣ ( ក) ។

# អនុសាសន៍ជាគោលការណ៍ទូទៅ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស

## គោលការណ៍ណែនាំទី១ : ការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស

ការរំលោភសិទ្ធិមនុស្ស គឺជាមូលហេតុ និងបច្ច័យផលដែលនាំឱ្យមានការជួញដូរមនុស្ស ។ ហេតុដូចនេះហើយ វាគឺជាការសំខាន់ក្នុងការចាត់វិធានការឱ្យបានកិរិតខ្ពស់បំផុតក្នុងកិច្ចការពារសិទ្ធិមនុស្ស ដើម្បីទប់ស្កាត់ និងបញ្ចប់អំពើជួញដូរមនុស្ស ។ វិធានការប្រឆាំងអំពើជួញដូរមនុស្ស មិនត្រូវឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅដល់សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សឡើយ ហើយជាពិសេស សិទ្ធិរបស់អ្នកដែលត្រូវគេជួញដូរ អន្តោប្រវេសន្ត ជនផ្លាស់ប្តូរទីលំនៅនៅក្នុងប្រទេស ជនភាសខ្លួន និង ជនសុំសិទ្ធិជ្រកកោននយោបាយ ។

**រដ្ឋទាំងឡាយ ហើយបើមាន អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល គួរយកចិត្តទុកដាក់ :**

១. ចាត់វិធានការនានាដើម្បីធានាថា វិធានការដែលបានអនុម័តសំរាប់ការទប់ស្កាត់ និងប្រឆាំងអំពើជួញដូរមនុស្ស មិនត្រូវឱ្យមានផលអវិជ្ជមានដល់សិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់មនុស្សឡើយ រាប់ទាំងអ្នកដែលត្រូវគេជួញដូរ ។

២. ពិគ្រោះយោបល់ជាមួយស្ថាប័នតុលាការ និងច្បាប់, វិទ្យាស្ថានសិទ្ធិមនុស្សថ្នាក់ជាតិ, និងសង្គមស៊ីវិលដែលពាក់ព័ន្ធ ក្នុងការបង្កើត អនុម័ត អនុវត្ត និងពិនិត្យច្បាប់ គោលនយោបាយ និងកម្មវិធីនានាប្រឆាំងអំពើជួញដូរមនុស្ស ។

៣. បង្កើតផែនការថ្នាក់ជាតិដើម្បីបញ្ចប់អំពើជួញដូរមនុស្ស ។ ដំណើរការនេះ គួរធ្វើឡើងដើម្បីបង្កើតឱ្យជាបណ្តាញ និងភាពជាដៃគូរ រវាងស្ថាប័នរដ្ឋាភិបាលដែលពាក់ព័ន្ធក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និង/ឬ ជួយដល់អ្នកដែលត្រូវគេជួញដូរ និង រវាងផ្នែកពាក់ព័ន្ធនៃសង្គមស៊ីវិល ។

៤. យកចិត្តទុកដាក់ជាពិសេស ដើម្បីធានាថា បញ្ហារើសអើងដោយឈរលើភេទ ត្រូវដោះស្រាយជាលក្ខណៈប្រព័ន្ធ នៅពេលវិធានការប្រឆាំងអំពើជួញដូរមនុស្សត្រូវបានស្នើឡើងដើម្បីធានាថា វិធានការទាំងអស់នេះ មិនត្រូវបានអនុវត្ត នៅក្នុងរបៀបរើសអើសឡើយ ។

៥. ការពារសិទ្ធិសេរីភាពដើរហើររបស់ជនគ្រប់រូប ហើយត្រូវធានាថា វិធានការប្រឆាំងអំពើជួញដូរមនុស្ស មិនត្រូវឱ្យមាន ផលប៉ះពាល់ដល់សិទ្ធិនេះឡើយ ។

៦. ធានាថា រាល់ច្បាប់ គោលនយោបាយ និងកម្មវិធី និងកិច្ចអន្តរាគមន៍នានាប្រឆាំងអំពើជួញដូរមនុស្ស មិនត្រូវឱ្យមានការប៉ះពាល់ដល់សិទ្ធិរបស់ជនគ្រប់រូប ដូចជា អ្នកដែលត្រូវគេជួញដូរ ក្នុងការស្វែងរក

និងទទួលបានសិទ្ធិជ្រកកោន ដើម្បីគេចឱ្យផុតពីការចោទប្រកាន់ ដោយយោងតាមច្បាប់អន្តរជាតិស្តីពីជនភាសខ្លួនជាពិសេស តាមរយៈនៃការអនុវត្តឱ្យមានប្រសិទ្ធិភាពនៃគោលការណ៍មិនបញ្ជូនត្រលប់មកប្រទេសកំណើតវិញ ។

៧. បង្កើតយន្តការនានា ដើម្បីពិនិត្យតាមដានពីផលប៉ះពាល់លើសិទ្ធិមនុស្សរបស់ ច្បាប់ គោលនយោបាយ និងកម្មវិធី និងកិច្ចអន្តរាគមន៍នានាប្រឆាំងអំពើជួញដូរមនុស្ស ។ បើអាចធ្វើទៅបាន ស្ថាប័នឯករាជ្យថ្នាក់ជាតិស្តីពីសិទ្ធិមនុស្សគួរត្រូវបានពិចារណា ផ្តល់តួនាទីនេះ ។ អង្គការមិនមែនរដ្ឋាភិបាលដែលបំពេញការងារជួយដល់អ្នកដែលត្រូវគេជួញដូរ គួរត្រូវបានលើកទឹកចិត្តឱ្យចូលរួមតាមដាន និងវាយតំលៃពីផលប៉ះពាល់លើសិទ្ធិមនុស្សរបស់វិធានការនានាប្រឆាំងអំពើជួញដូរមនុស្ស ។

៨. បង្ហាញព័តមានលំអិតនៅក្នុងរបាយការណ៍តាមពេលវេលាជាក់លាក់ ពាក់ព័ន្ធទៅនឹងវិធានការទប់ស្កាត់ និងប្រឆាំងអំពើជួញដូរមនុស្ស ដល់ស្ថាប័នតាមដានពិនិត្យសិទ្ធិសញ្ញាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ [៥] ។

៩. ធានាថា កិច្ចព្រមព្រៀងសហប្រតិបត្តិការជាលក្ខណៈទ្វេរភាគី តំបន់ និងអន្តរជាតិ និងច្បាប់ និងគោលនយោបាយដទៃទៀតពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស មិនត្រូវឱ្យមានផលប៉ះពាល់ដល់ សិទ្ធិ កាតព្វកិច្ច ឬ ការទទួលខុសត្រូវរបស់រដ្ឋនានា យោងតាមច្បាប់អន្តរជាតិឡើយ រួមមាន ច្បាប់ស្តីពីសិទ្ធិមនុស្ស ច្បាប់ស្តីពីមនុស្សធម៌ និងច្បាប់ស្តីពីជនភាសខ្លួន ។

១០. ផ្តល់កិច្ចគាំទ្រខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់រដ្ឋទាំងឡាយ និងស្ថាប័នសង្គមស៊ីវិលពាក់ព័ន្ធនានា ដើម្បីបង្កើត និងអនុវត្តយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស ដោយឈរលើគោលការសិទ្ធិមនុស្ស ។

## គោលការណ៏ណែនាំទី២ : ការកំណត់ជនណាជាជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងជនជួញដូរ

**ការជួញដូរមនុស្ស មានន័យច្រើនជាងការបំលាស់ទីមនុស្សដោយទទួលបានអត្ថប្រយោជន៏ ។ កត្តាបន្ថែមសំខាន់គឺថា ការបែងចែកពីភាពខុសគ្នារវាង ការជួញដូរមនុស្សនិងការរត់ពន្ធមនុស្ស គឺតំរូវឱ្យមានការបង្ហាញនូវការប្រើកំលាំង ការបង្ខំ និងឬ ការបោកប្រាស់ ឬ នៅដំណាក់កាលខ្លះនៃដំណើរការជួញដូរ ដូចជា ការបោកប្រាស់ ការប្រើកំលាំង ឬការបង្ខំ**

---

៥. ស្ថាប័នតាមដានពិនិត្យសិទ្ធិសញ្ញាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ រួមមាន គណៈកម្មាធិការសិទ្ធិមនុស្ស , គណៈកម្មាធិការស្តីពីសិទ្ធិខាងផ្នែកសេដ្ឋកិច្ច សង្គម និងវប្បធម៌, គណៈកម្មាធិការស្តីពីការលុបបំបាត់ចោលរាល់ទំរង់រើសអើងប្រឆាំងនឹងស្ត្រី, គណៈកម្មាធិការស្តីពីការលុបបំបាត់ចោលរាល់ទំរង់រើសអើងប្រឆាំងនឹងពូជសាសន៏, គណៈកម្មាធិការប្រឆាំងនឹងការធ្វើទារុណកម្ម, គណៈកម្មាធិការស្តីពីសិទ្ធិរបស់កុមារ ។

**ដែលប្រើប្រាស់ក្នុងគោលបំណងកេងប្រវ័ញ្ច ។ ទោះបីជាការបន្ថែមធាតុផ្សំខ្លះ ដែលធ្វើឱ្យមានភាពខុសគ្នា យ៉ាងច្បាស់រវាង ការជួញដូរមនុស្សនិងការរត់ពន្ធមនុស្សក៏ដោយ ក៏មាននៅក្នុងរឿងក្ដីជាច្រើន ដែលធ្វើឱ្យមានការពិបាក ក្នុងការបែងចែកភាពខុសគ្នា ដែលបញ្ហានេះតំរូវឱ្យមានការស៊ើបអង្កេតយ៉ាងសកម្ម ។ ការមិនបានកំណត់ ជនណាមួយថា ជាជនរងគ្រោះឱ្យបានត្រឹមត្រូវ គឺអាចនាំឱ្យមានការបដិសេធ សិទ្ធិរបស់ពួកគេដែលមាននៅពេលលខាងមុខ ។ ដូចនេះ រដ្ឋត្រូវមានកាតព្វកិច្ច ដើម្បីធានាថា ការកំណត់ជនណាមួយថាជាជនរងគ្រោះ គឺអាចធ្វើទៅបាន ។**

**រដ្ឋទាំងអស់ត្រូវមានកាតព្វកិច្ចផងដែរ ក្នុងការកំណត់ឱ្យបានត្រឹមត្រូវនូវជនណាមួយ ថាជាជនល្មើសជួញដូរមនុស្ស រួមទាំងជនដែលមានការពាក់ព័ន្ធទៅនឹង ការគ្រប់គ្រង និងការកេងប្រវ័ញ្ចលើជនដែលត្រូវគេជួញដូរ ។**

**បើអាចធ្វើទៅបាន រដ្ឋ និងអង្គការអន្តររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល គួរតែពិចារណា ទៅលើ :**

១. បង្កើតគោលការណ៍ និងនីតិវិធី ដល់អាជ្ញាធររដ្ឋ និងមន្ត្រីរបស់រដ្ឋ ដូចជា នគរបាល អ្នកការពារព្រំដែន មន្ត្រីអន្តោប្រវេសន្ត និង អ្នកដែលពាក់ព័ន្ធ ក្នុងការស្វែងរក ឃុំឃាំង ទទួល និងចាត់វិធានការទៅលើ ចំណាកស្រុកខុសច្បាប់, ដើម្បីឱ្យអ្នកទាំងនោះអាចកំណត់ឱ្យបានឆាប់ និងមានភាពពិតប្រាកដ ថាតើជនណាមួយ ត្រូវបានគេជួញដូរ ។

២. ផ្តល់ការបណ្តុះបណ្តាលសមរម្យដល់អាជ្ញាធររដ្ឋ និងមន្ត្រីរបស់រដ្ឋ នៅក្នុងការកំណត់ជនដែលត្រូវគេជួញដូរ និងអនុវត្តឱ្យបានត្រឹមត្រូវលើគោលការណ៍ និងនីតិវិធីខាងលើ ។

៣. ធានាឱ្យមានកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរ មន្ត្រី និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសំរបសំរួលលើការកំណត់ និងផ្តល់ជំនួយដល់ជនដែលត្រូវគេជួញដូរ ។ ការរៀបចំ និងការអនុវត្តលើកិច្ចសហប្រតិបត្តិការបែបនេះ គួរតែធ្វើឡើង ដើម្បីបង្កើតឱ្យបានជាអតិបរមានូវប្រសិទ្ធិភាពរបស់ខ្លួន ។

៤. កំណត់ពីចំណុចសមរម្យនៃកិច្ចអន្តរាគមន៍ ដើម្បីធានាថា ជនចំណាកស្រុក និងជនចំណាកស្រុកសំខាន់ៗ ត្រូវបានគេព្រមានអំពីភាពដែលអាចកើតមានគ្រោះថ្នាក់ និងផលវិបាកនៃការជួញដូរមនុស្ស និងការទទួលព័ត៌មាន ដែលអាចធ្វើឱ្យគេរកអ្នកជួយបាន ប្រសិនបើស្ថានភាពតំរូវ ។

៥. ធានាថា ជនដែលត្រូវគេជួញដូរ មិនត្រូវបានគេចោទប្រកាន់ពីការរំលោភច្បាប់អន្តោប្រវេសន្តឡើយ ឬពីសកម្មភាព ដែលខ្លួនមានការពាក់ព័ន្ធ នៅពេលជនរងគ្រោះស្ថិតនៅក្នុងស្ថានភាពជាអ្នកដែលត្រូវគេជួញដូរ ។

៦. ធានាថា ជនដែលត្រូវគេជួញដូរ នៅក្នុងស្ថានភាពណាក៏ដោយ មិនត្រូវជាប់ឃុំឃាំងអន្តោប្រវេសន្តឡើយ ឬ ទំរង់ផ្សេងៗទៀតនៃការឃុំឃាំង ។

៧. ធានាឱ្យមាននីតិវិធី និងដំណើរការ សំរាប់ទទួល និងពិចារណាទៅលើ សំណើរសុំសិទ្ធិជ្រកកោនពីជនដែលត្រូវគេជួញដូរ និងអ្នកដែលត្រូវគេរត់ពន្ធ ដើម្បីស្វែងរកសិទ្ធិជ្រកកោន ហើយត្រូវធានាថា គោលការមិនបញ្ជូនមកព្រំដែនវិញ ត្រូវបានគោរពនិងយល់ព្រម គ្រប់ពេលវេលា ។

ជាការបន្ថែមទៅនឹងអនុសាសន៍ជាគោលការណ៍ទូទៅ និងជាគោលការណ៍ណែនាំ ស្តីពីសិទ្ធិមនុស្ស និងការជួញដូរមនុស្ស បានចែងពីកិច្ចការពារ និងកិច្ចគាំពារដល់ជនរងគ្រោះ ដោយសារអំពើជួញដូរមនុស្ស ដូចខាងក្រោមៈ

## គោលការណ៍ណែនាំទី៣ ៖ ការសិក្សាស្រាវជ្រាវ វិភាគ វាយតំលៃ និងការចែករំលែកពត៌មាន

**យុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្សដ៏មានប្រសិទ្ធិភាព និងដែលអាចជឿជាក់បាន ត្រូវអាស្រ័យលើព័តមាន បទពិសោធន៍ និងការវិភាគច្បាស់លាស់ និងថ្មីៗ ។ វាគឺជាការសំខាន់ដែលថា រាល់ភាគីដែលមានការពាក់ព័ន្ធទៅនឹងបង្កើត និងអនុវត យុទ្ធសាស្ត្រទាំងនេះ បានយល់ដឹងច្បាស់លាស់ពីបញ្ហាទាំងអស់នេះ ។**

**ប្រព័ន្ធផ្សព្វផ្សាយព័តមាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនការយល់ដឹងជាសាធារណៈពីបុព្វហេតុនៃអំពើជួញដូរមនុស្ស ដោយផ្តល់នូវព័តមានច្បាស់លាស់តាមស្តង់ដាក្រមសីលធម៌វិជ្ជាជីវៈ ។**

**បើអាចធ្វើទៅបាន រដ្ឋ និងអង្គការអន្តររដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាល គួរតែពិចារណា ទៅលើ ៖**

១. អនុម័ត និងប្រើប្រាស់ឱ្យបានស៊ីសង្វាក់គ្នានូវនិយមន័យនៃអំពើជួញដូរមនុស្សដែលបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ចែងនៅក្នុងពិធីសារប៉ាលឺម៉ូ [៦]។

---

[៦] ពិធីសារស្តីពីស្តីពីការទប់ស្កាត់ បង្ក្រាប និងផ្តន្ទាទោសអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រីនិងកុមារ (ពិធីសារប៉ាលឺម៉ូ) បំពេញបន្ថែមលើអនុសញ្ញាសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋឆ្លងដែន ។ និយមន័យនៃពាក្យ " ការជួញដូរមនុស្ស " ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកមនុស្ស ដោយមធ្យោបាយគំរាមកំហែង ឬការប្រើកំលាំង ឬការបង្ខិតបង្ខំតាមរូបភាពផ្សេងៗ ដូចជាការចាប់ពង្រត់ ការក្លែងបន្លំ ការបោកបញ្ឆោត ការរំលោភលើអំណាច ឬតួនាទីទៅលើជនដែលងាយទទួលរងគ្រោះ ឬការផ្តល់ ឬការទទួលជាលុយកាក់ ឬផលកំរៃផ្សេងៗដើម្បីអោយមានការយល់ព្រមពីអ្នកគ្រប់គ្រងលើជនម្នាក់ទៀត ក្នុងគោលបំណងដើម្បីធ្វើអាជីវកម្ម។ អាជីវកម្មត្រូវរាប់បញ្ចូលជា អប្បបរិមានូវការធ្វើអាជីវកម្មពេស្យាចារលើអ្នកដទៃ ឬការធ្វើអាជីវកម្មផ្លូវភេទតាមរូបភាពផ្សេងទៀត ការងារដោយបង្ខំ ឬសេវាកម្មទាសភាព ឬការអនុវត្តដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងទាសភាព ភាពជាអ្នកបំរើដាច់ថ្លៃ ឬការលក់ដូរសរីរាង្គជាដើម ។

២. ប្រមូលព័តមានទិន្ន័យឱ្យមានលក្ខណៈស្តង់ដា ស្តីពីការជួញដូរមនុស្ស និងការចំណាកស្រុកដែលពាក់ព័ន្ធ (ដូចជា អំពើរត់ពន្ធទេសន្តប្រវេសន្ត) ដែលអាចបញ្ចូលជាធាតុផ្សំមួយនៃអំពើជួញដូរមនុស្ស ។

៣. ធានាថា ទិន្ន័យពាក់ព័ន្ធនឹងអ្នកដែលត្រូវគេជួញដូរ គឺត្រូវបែងចែកទៅតាម អាយុ ភេទ ជាតិសាន៍ និង តាមបុគ្គលិកលក្ខណៈផ្សេងៗទៀត ។

៤. អនុវត្ត គាំទ្រ និងរួមគ្នាសិក្សាស្វែងរកពីបញ្ហាជួញដូរមនុស្ស ។ ការសិក្សាទាំងនេះ គឺត្រូវយក គោលការណ៍ក្រមសីលធមិជាគោល ដូចជា ការយល់ដឹងពីសេចក្តីត្រូវការនៃការមិនឱ្យជនរងគ្រោះ ទទួលរងគ្រោះ ខាងផ្នែកផ្លូវចិត្តម្តងទៀត ។វិធីសាស្ត្រនៃការស្រាវជ្រាវ និងបច្ចេកទេសនៃការបកស្រាយ ត្រូវមានគុណភាពខ្ពស់ ។

៥. វាយតំលៃនិងតាមដានពីទំនាក់ទំនងរវាងគោលបំណងនៃ ច្បាប់ គោលនយោបាយ និងកិច្ចអន្តរាគមន៏នានាប្រឆាំងនឹង អំពើជួញដូរមនុស្ស និងផលប៉ះពាល់ពិតប្រាកដរបស់វា ។ ជាពិសេស ត្រូវធានាឱ្យមានការបែងចែកច្បាស់លាស់ពី វិធានការដែលមានការកាត់បន្ថយពិតប្រាកនូវអំពើជួញដូរមនុស្ស និងវិធានការដែលគ្រាន់តែផ្ទេរបញ្ហាពីកន្លែងមួយ ទៅកន្លែងមួយទៀត ឬ ផ្ទេរពីក្រុមមួយទៅក្រុមមួយទៀត។

៦. ទទួលស្គាល់ពីការចូលរួមយ៉ាងសំខាន់របស់អ្នករួចខ្លួនពីការជួញដូរ អាចបង្កើតនិងអនុវត្តកិច្ចអន្តរាគមន៏ប្រឆាំង អំពើជួញដូរមនុស្ស និងវាយតំលៃពីផលប៉ះពាល់ទាំងនេះ តែអាចធ្វើទៅបានអាស្រ័យលើការយល់ព្រមដោយស្ម័គ្រចិត្ត ពីជនរងគ្រោះតែប៉ុណ្ណោះ ។

៧. ទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់អង្គការមិនមែនរដ្ឋាភិបាលដែលអាចដើរតួនាទី ក្នុងការជំរុញការអនុវត្តច្បាប់ប្រឆាំង អំពើជួញដូរមនុស្ស ដោយតាមរយៈការផ្តល់អំណាចឱ្យអង្គការមិនមែនរដ្ឋាភិបាលក្នុងការរក្សាព័តមាន ជាលក្ខណៈឯកជនរបស់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ពាក់ព័ន្ធទៅនឹងព័តមាន ឬផ្នែកណាមួយនៃព័តមាន ជួញដូរមនុស្ស ដែលជនរងគ្រោះរៀបរាប់ប្រាប់។

---

ប្រភពឯកសារៈ ពិធីសារស្តីពីការទប់ស្កាត់ ការបង្រ្កាប និង ការផ្តន្ទាទោសការជួញដូរមនុស្សជាពិសេសស្ត្រី និង កុមារបន្ថែមលើ អនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (មាត្រា ៣ (ក) ។ ពិធីសារបានចែងបន្ថែមទៀតថា ការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកកុមារ ក្នុងគោលបំណងធ្វើអាជីវកម្ម ត្រូវចាត់ទុកថាជា " ការជួញដូរមនុស្ស" ទោះបីជាអំពើនេះមិនជាប់ពាក់ពន្ធ័ទៅនឹង មធ្យោបាយណាមួយ ដែលមានចែងក្នុងវាក្យខ័ណ្ឌខាងលើនៃមាត្រានេះក៏ដោយ (មាត្រា ៣.គ) ។

## គោលការណ៍ណែនាំទី ៤ : ធានាឱ្យមានក្របខ័ណ្ឌច្បាប់សមស្រប

**កង្វះខាតច្បាប់ពិសេស និង/ឬ ច្បាប់សមស្រប នៅថ្នាក់ជាតិ ត្រូវបានកំណត់ថា ឧបសគ្គចំបងមួយក្នុងចំណោមឧបសគ្គនានាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ការកំណត់និយមន័យ នីតិវិធី និងកិច្ចសហប្រតិបត្តិការឱ្យមានភាពស៊ីសង្វាក់គ្នា នៅថ្នាក់ជាតិ ថ្នាក់តំបន់ ឱ្យស្របទៅនឹងស្តង់ដាអន្តរជាតិ គឺជាសេចក្តីត្រូវការបន្ទាន់មួយ ។ ការបង្កើតក្របខ័ណ្ឌច្បាប់សមរម្យសមស្របទៅនឹងឧបករណ៍ និងស្តងដាអន្តរជាតិពាក់ព័ន្ធ នឹងដើរតួនាទីយ៉ាងសំខាន់ដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានាដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ។**

**រដ្ឋនានា គួរយកចិត្តទុកដាក់ :**

១. វិសោធនកម្ម និង អនុម័ត ច្បាប់ជាតិ ឱ្យស្របទៅនឹងស្តង់ដាអន្តរជាតិ ធ្វើដូចនេះ បទល្មើសជួញដូរមនុស្ស អាចកំណត់ និងចែងជាក់លាក់នៅក្នុងច្បាប់ជាតិ និងគោលការណ៍លំអិតនានា ដោយមានធាតុផ្សំបទល្មើសផ្សេងៗ។ រាល់អំពើនានាដែលមានចែងនៅក្នុងនិយមន័យនៃអំពើជួញដូរមនុស្ស ដូចជា បំណុលដោយមានការបង្ខំ ការងារដោយបង្ខំ និងពេស្យាចារដោយបង្ខំ គួរត្រូវបានចែងជាបទល្មើសព្រហ្មទណ្ឌ ។

២. អនុម័តច្បាប់ដោយចែងឱ្យមានការទទួលខុសត្រូវខាងផ្នែករដ្ឋបាល រដ្ឋប្បវេណី និង បើអាចធ្វើទៅបាន ការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌរបស់នីតិបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើសជួញដូរមនុស្ស បន្ថែមទៅនឹង ការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ។ ពិនិត្យច្បាប់ ការគ្រប់គ្រង និងលក្ខខណ្ឌរដ្ឋបាលនានា ពាក់ព័ន្ធទៅនឹង ការចេញអាជ្ញាបណ្ណ និងការធ្វើអាជីវកម្ម ដែលជាការបិទបាំងនូវអំពើជួញដូរមនុស្ស ដូចជា ការិយាល័យរៀបចំអាពាហ៍ពិពាហ៍ ទីភ្នាក់ងាររកការងារ ទីភ្នាក់ងារទេសចរ សេវាសណ្ឋាគារ និងជូនភ្ញៀវ ។

៣. រៀបចំច្បាប់ឱ្យមានការផ្តន្ទាទោសបានប្រសិទ្ធិភាព និងសមាមាត្រ (រួមមាន ការឃុំខ្លួនដែលអាចឱ្យមាន ការធ្វើបត្យាប័នជននោះ ) ។ បើអាចធ្វើទៅបាន បទបញ្ញាតិច្បាប់គួរចែងស្ថានទម្ងន់ទោស ក្នុងករណីរកឃើញថា ជនណាមួយបានប្រព្រឹត្តិបទល្មើសធ្ងន់ធ្ងរ ដូចជា បទល្មើសពាក់ព័ន្ធនឹងការជួញដូរកុមារ ឬបទល្មើសបានប្រព្រឹត្តិ ឡើងដោយ ឬមានការពាក់ព័ន្ធទៅនឹងមន្ត្រីសាធារណៈ ។

៤. រៀបចំច្បាប់ឱ្យមានការរឹបអូស និងដំណើរការនៃបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធ ។ បើអាចធ្វើទៅបាន ច្បាប់គួរចែងឱ្យច្បាស់ថា ដំណើរការរឹបអូសនៃរឿងក្តីជួញដូរមនុស្ស នឹងត្រូវប្រើប្រាស់ជាអត្ថប្រយោជន៍ដល់ជនរងគ្រោះ

ដោយសារអំពើជួញដូរមនុស្ស ។ មូលនិធិសំណងដល់ជនរងគ្រោះ គួរពិចារណាដើម្បីបង្កើតឱ្យមានឡើង ដោយប្រើប្រាស់ទ្រព្យសម្បត្តិបានមកពីការរឹបអូសនៅក្នុងរឿងក្តីជួញដូរមនុស្ស ។

៥. ធានាឱ្យមានច្បាប់ទប់ស្កាត់កុំឱ្យមានការចោទប្រកាន់ ឃុំឃាំង ឬ ផ្តន្ទាទោសជនដែលត្រូវគេជួញដូរ ពីបទអន្តោប្រវេសន៍ខុសច្បាប់ ឬ ស្នាក់នៅខុសច្បាប់ ឬពិសកម្មភាពចេញមកពីស្ថានភាពដោយផ្ទាល់របស់ជនដែលត្រូវគេជួញដូរនោះ ។

៦. ធានាថា កិច្ចការពារជនដែលត្រូវគេជួញដូរ គឺមាននៅក្នុងច្បាប់ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស រួមមានកិច្ចការពារពីនិរទេស ឬបញ្ជូនត្រលប់ទៅទីកន្លែងដែលគេជឿជាក់ថា ការនិរទេស ឬបញ្ជូនត្រលប់ទៅទីនោះ នឹងមានគ្រោះថ្នាក់ខ្លាំងដល់ជនដែលត្រូវគេជួញដូរ ឬ ក្រុមគ្រួសាររបស់គេ ។

៧. រៀបចំច្បាប់ឱ្យមានកិច្ចការពារដល់ជនរងគ្រោះដែលស្ម័គ្រចិត្តយល់ព្រមសហការជាមួយមន្ត្រីអនុវត្តច្បាប់ រួមមានកិច្ចការពារសិទ្ធិឱ្យស្នាក់នៅស្របច្បាប់នៅក្នុងប្រទេសគោលដៅនៃអំពើជួញដូរមនុស្ស នៅក្នុងអំឡុងពេលដំណើរការនីតិវិធីច្បាប់ ។

៨. រៀបចំច្បាប់ឱ្យមានការផ្តល់ព័តមាន និងកិច្ចគាំទ្រខាងផ្នែកច្បាប់ ជាភាសាដែលជនរងគ្រោះដោយសារអំពើជួញដូរអាចយល់បាន ព្រមទាំងកិច្ចគាំទ្រខាងផ្នែកសង្គមគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាបន្ទាន់របស់គេ ។ រដ្ឋត្រូវធានាថា ការផ្តល់ព័តមាន កិច្ចគាំទ្រ និងជំនួយបន្ទាន់ គឺមិនត្រូវធ្វើឡើងដោយមានការរើសអើងនោះទេ ប៉ុន្តែវាគឺជាសិទ្ធិទទួលបានសំរាប់ជនគ្រប់រូបដែលត្រូវបានកំណត់ថា ជាជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ។

៩. ត្រូវធានាថា សិទ្ធិរបស់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ក្នុងការប្តឹងតវ៉ាទាមទារសំណងជំងឺចិត្តពីជនជួញដូរមនុស្ស គឺមានចែងនៅក្នុងច្បាប់ ។

១០. ត្រូវធានាថា កិច្ចការពារសាក្សី មានចែងនៅក្នុងច្បាប់ ។

១១. រៀបចំច្បាប់ឱ្យមានការផ្តន្ទាទោសដល់មន្ត្រីសាធារណៈដែលមានការពាក់ព័ន្ធ ឬសមគំនិតក្នុងរឿងក្តីជួញដូរមនុស្ស ឬការកេងប្រវ័ញ្ចនានានៅក្នុងរឿងក្តីជួញដូរមនុស្ស ។

## គោលការណ៍ណែនាំទី ៥ : ការធានាឲ្យមានការឆ្លើយតបសមស្របពីស្ថាប័នអនុវត្តច្បាប់

ទោះបីជាមានភស្តុតាងបញ្ជាក់ថា អំពើជួញដូរមនុស្សកំពុងតែកើនឡើងនៅក្នុងតំបន់ទាំងអស់នៅក្នុងពិភពលោក ប៉ុន្តែមានជនជួញដូរមនុស្សមួយចំនួនតូចត្រូវបានចាប់ខ្លួន ។ ស្ថាប័នអនុវត្តច្បាប់កាន់តែខ្លាំង នឹងអាចទប់ស្កាត់អំពើរបស់ជនជួញដូរមនុស្ស ហើយនឹងមានផលប៉ះពាល់ដោយផ្ទាល់លើសេចក្តីតំរូវការនៃអំពើជួញដូរមនុស្ស ។

ការឆ្លើយតបសមស្របរបស់ស្ថាប័នអនុវត្តច្បាប់លើបញ្ហាជួញដូរមនុស្ស គឺអាស្រ័យទាំងស្រុងទៅលើកិច្ចសហប្រតិបត្តិការពីជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស និងសាក្សីដទៃទៀត ។ នៅក្នុងរឿងក្តីជួញដូរមនុស្សជាច្រើន អ្នកពាក់ព័ន្ធមានការស្ទាក់ស្ទើរ ឬមិនអាចរាយការណ៍ពីជនជួញដូរមនុស្ស ឬធ្វើជាសាក្សីឡើយ ពីព្រោះពួកគេមិនមានជំនឿទៅលើនគរបាល និងប្រព័ន្ធតុលាការឡើយ និង/ឬ ដោយសារគ្មានយន្តការស្តីពីការពារប្រកបដោយប្រសិទ្ធិភាព ណាមួយឡើយ ។ បញ្ហាទាំងអស់នេះគឺធ្ងន់ធ្ងរទៅទៀត នៅពេលមន្ត្រីអនុវត្តច្បាប់មានការពាក់ព័ន្ធ ឬ អំពើសមគំនិត នៅក្នុងអំពើជួញដូរមនុស្ស ។ វិធានការខ្លាំងមួយត្រូវធ្វើឡើងដើម្បីធានាថា ការពាក់ព័ន្ធបែបនេះត្រូវតែមានការស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោស ។ មន្ត្រីអនុវត្តច្បាប់ តំរូវឲ្យមានការធានាសុវត្ថភាពខ្ពស់ខ្លាំងបំផុតចំពោះជនរងគ្រោះដោយសារការជួញដូរមនុស្ស ។ ការទទួលខុសត្រូវបែបនេះ គឺជាភារកិច្ចរបស់អ្នកស៊ើបអង្កេត ហើយមិនអាចលើកលែងការទទួលខុសត្រូវបានឡើយ ។

**រដ្ឋ បើអាចធ្វើទៅបាន អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល គួរពិចារណា :**

១. ត្រូវធ្វើឲ្យស្ថាប័ននិងមន្ត្រីអនុវត្តច្បាប់ យកចិត្តទុកដាក់ជាចំបងនូវការទទួលខុសត្រូវរបស់ខ្លួន ដើម្បីធានាសុវត្ថភាពសុខមាលភាពជាបន្ទាន់របស់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ។

២. ធានាថា មន្ត្រីអនុវត្តច្បាប់ទទួលបាននូវការបណ្តុះបណ្តាលសមរម្យក្នុងការស៊ើបអង្កេត និងចោទប្រកាន់ នៅក្នុងរឿងក្តីជួញដូរមនុស្ស ។ ការបណ្តុះបណ្តាលគួរយកចិត្តទុកដាក់ពីសេចក្តីត្រូវការរបស់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ជាពិសេស ស្ត្រី និងកុមារ និងគួរទទួលស្គាល់ពីតំលៃ និងអត្ថប្រយោជន៍ដល់ជនរងគ្រោះដោយសារការជួញដូរ និង អ្នកដ៏ទៃទៀតដែលរាយការណ៍ពីជនជួញដូរមនុស្ស ។ ការពាក់ព័ន្ធរបស់អង្គការមិនមែនរដ្ឋាភិបាល នៅក្នុងការបណ្តុះបណ្តាលនេះ គឺជាមធ្យោបាយបង្កើននូវការពាក់ព័ន្ធ និងប្រសិទ្ធិភាពរបស់ខ្លួន។

៣. ផ្តល់ដល់ស្ថាប័នអនុវត្តច្បាប់នូវអំណាចស៊ើបអង្កេតគ្រប់គ្រាន់ និងបច្ចេកទេសនានាដើម្បីស៊ើបអង្កេត និងចោទប្រកាន់បានលើជនសង្ស័យនៅក្នុងរឿងក្តីជួញដូរមនុស្ស ។ រដ្ឋគួរលើកទឹកចិត្តនិងគាំទ្រដល់ការបង្កើតនីតិវិធីស៊ើបអង្កេតមុនបទល្មើសកើតឡើង គឺវាអាចជៀសវាងបានលើការស៊ើបអង្កេត និងចោទប្រកាន់នានាដែលពឹងផ្អែកខ្លាំងពេកលើចំលើយសាក្សីរបស់ជនរងគ្រោះ ។

៤. បង្កើតអង្គភាពឯកទេសប្រឆាំងអំពើជួញដូរមនុស្ស (រួមមានសមាជិក ទាំងបុរស និងស្ត្រី) ដើម្បីលើកកំពស់ដល់សមត្ថភាព និងអាជីពឯកទេស ។

៥. ធានាថា ជនជួញដូរមនុស្ស ស្ថិតនៅ ហើយនឹងនៅតែជាកម្មវត្ថុនៃការផ្តោតយកចិត្តទុកដាក់លើយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស ហើយ កិច្ចខិតខំប្រឹងប្រែងរបស់មន្ត្រីអនុវត្តច្បាប់មិនត្រូវធ្វើឱ្យជនរងគ្រោះ មានគ្រោះថ្នាក់ដល់ទទួលរងនូវទោស ដែលជនរងគ្រោះបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនត្រូវគេជួញដូរនោះទេ ។

៦. ការអនុវត្តវិធានការត្រូវធានាថា កិច្ចប្រតិបត្តិការ " សង្គ្រោះ" មិនត្រូវបន្តប៉ះពាល់ដល់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះដោយសារអំពើជួញដូរមនុស្សឡើយ ។ កិច្ចប្រតិបត្តិការបែបនេះ គួរធ្វើឡើង ទៅតាមនីតិវិធីសមរម្យ និងសមស្របដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការឱ្យមានការដោះលែងរបស់ជនរងគ្រោះដោយសារការជួញដូរ ។

៧. ត្រូវឱ្យមានការយកចិត្តទុកដាក់ពី នគរបាល ព្រះរាជអាជ្ញា អាជ្ញាធរព្រំដែន អន្តោប្រវេសន្ត តុលាការ អ្នកបំរើការងារសុខាភិបាលសង្គម និងសាធារណៈ លើបញ្ហាជួញដូរមនុស្ស និងធានាឱ្យមានការបណ្តុះបណ្តាលជាលក្ខណៈឯកទេស ក្នុងការកំណត់ថារឿងក្តីណាមួយថាជារឿងជួញដូរមនុស្ស, និងយកចិត្តទុកដាក់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារសិទ្ធិរបស់ជនរងគ្រោះ ។

៨. ប្រឹងប្រែងឱ្យបានសមស្របក្នុងកិច្ចការពារអ្នកដែលត្រូវគេជួញដូរ នៅក្នុងដំណើរការស៊ើបអង្កេត និងសវនការរឿងក្តី និងរយៈពេលបន្តមកទៀត បើតំរូវឱ្យមានកិច្ចការពារសុវត្ថិភាពរបស់អ្នកដែលត្រូវគេជួញដូរ ។ កម្មវិធីស្តីពីកិច្ចការពារសមស្រប គួរមាន ធាតុផ្សំមួយចំនួន ឬធាតុផ្សំទាំងអស់ដូចខាងក្រោមៈ កំណត់ទីកន្លែងសុវត្ថិភាពនៅក្នុងប្រទេសគោលដៅ, ទទួលបានការប្រឹក្សាច្បាប់ដែលមានលក្ខណៈឯករាជ្យ, កិច្ចការពារអត្តសញ្ញាណនៅពេលដំណើរការនីតិវិធីច្បាប់, កំណត់ឱ្យឃើញពីជំរើសនានានៅក្នុងការស្នាក់នៅបន្ត, ការផ្លាស់ប្តូរទីកន្លែង ឬការធ្វើមាតុភូមិនិវត្ត ។

៩. លើកទឹកចិត្តអាជ្ញាធរអនុវត្តច្បាប់ ឱ្យធ្វើការជាដៃគូរជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាថាអ្នកដែលត្រូវគេជួញដូរ ទទួលបាននូវកិច្ចគាំទ្រ និងជំនួយចាំបាច់ ។

## គោលការណ៍ណែនាំទី៦: កិច្ចការពារ និងកិច្ចគាំពារដល់ជនដែលត្រូវគេជួញដូរ

វដ្តនៃការកកើតឡើងវិញនៃអំពើជួញដូរមនុស្ស មិនអាចបំបាត់ចោលបានទេ ដោយគ្មានការយកចិត្តទុកដាក់ពីសិទ្ធិនិងសេចក្តីត្រូវការជាចាំបាច់ របស់អ្នកដែលត្រូវគេជួញដូរនោះ ។ កិច្ចការពារ និងកិច្ចគាំទ្រដ៏សមរម្យ គួរតែត្រូវបានផ្តល់ជូនដល់ជនដែលត្រូវគេជួញដូរទាំងអស់ ដោយគ្មានការរើសអើងឡើយ ។

**រដ្ឋ បើអាចមាន អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល គួរតែពិចារណាលើ វិធានការនានាដូចខាងក្រោម:**

១. ដោយមានការសហការគ្នាជាមួយអង្គការមិនមែនរដ្ឋាភិបាល រដ្ឋត្រូវធានាឱ្យមាន ជំរកគ្រប់គ្រាន់ និងមានសុវត្ថភាព ដែលបំពេញសេចក្តីត្រូវការជាចាំបាច់ របស់ជនដែលត្រូវគេជួញដូរ។ ការផ្តល់ជំរកបែបនេះ មិនត្រូវធ្វើឡើង ដោយមានលក្ខណៈថា ទាល់តែជនរងគ្រោះសុខចិត្តធ្វើជាសាក្សី ឬដើមបណ្តឹងក្នុងរឿងក្តីនៅតុលាការឡើយ។ ជនត្រូវគេជួញដូរ មិនគួរត្រូវឃុំឃាំង នៅក្នុងមណ្ឌលឃុំឃាំង ជនអន្តោប្រវេសន៍ ឬមន្ទីរឃុំឃាំងដទៃទៀត ឬ ផ្ទះសំរាប់ឱ្យជនពនេចរស្នាក់នៅឡើយ ។

២. ដោយមានសហការគ្នាជាដៃគូរជាមួយអង្គការមិនមែនរដ្ឋាភិបាលផង ធានាថា ជនត្រូវគេជួញដូរត្រូវតែទទួលបាន ការថែទាំសុខភាព និងការពិគ្រោះយោបល់ផ្សេងៗ ។ ជនត្រូវគេជួញដូរ មិនគួរតំរូវឱ្យ ទទួលការគាំទ្រ ឬជំនួយ (ដែលគេមិនចង់បាន) ហើយមិនត្រូវបានបង្ខំឱ្យធ្វើការសាកល្បងក្រែងមាន រោគ ដូចជា រោគហ៊ីវ-អេដស៍ឡើយ ។

៣. ធានាថា ជនត្រូវគេជួញដូរ ត្រូវបានពន្យល់ប្រាប់ពីភាពមានសិទ្ធិទៅជួប អ្នកតំណាងនៅស្ថានទូត ឬស្ថានកុងស៊ុល នៃប្រទេសរបស់ខ្លួន ។ បុគ្គលិកធ្វើការនៅស្ថានទូត ឬស្ថានកុងស៊ុល គួរតែត្រូវបានទទួលការអប់រំពីរឿងនេះ ដើម្បីឱ្យគេមានលទ្ធភាពឆ្លើយតបទៅនឹងពតិមាន ឬផ្តល់ជំនួយដល់ជនដែលទទួលរងការជួញដូរនោះត្រូវការ ។ ការផ្តល់ជំនួយបែបនេះ មិនត្រូវយកទៅប្រើជាមួយ ជនដែលត្រូវគេនាំរត់ឆ្លងដែន ដើម្បីស្វែងរកសិទ្ធជ្រកកោនឡើយ ។

៤. ធានាថា ដំណើរការជំរះក្តី ដែលមានការពាក់ព័ន្ធនឹងជនដែលត្រូវគេជួញដូរ នឹងមិនត្រូវវាយតំលៃទុកជាមុន ដែលនាំឱ្យបំពាល់ដល់សេចក្តីថ្លៃថ្នូរ និងសុខមាលភាពខាងផ្លូវកាយ និងផ្លូវចិត្តរបស់គេឡើយ ។

៥. ផ្តល់ជូនជនដែលត្រូវគេជួញដូរ នូវជំនួយផ្នែកច្បាប់ និងជំនួយផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌ រដ្ឋប្បវេណីយ និងបណ្តឹងផ្សេងៗទៀត ប្រឆាំងនឹងជនជួញដូរមនុស្ស ឬអ្នកកេងប្រវ័ញ្ចនោះ ។ ជនដែលត្រូវគេជួញដូរ គួរតែទទួលបានពតិមានជាភាសាដែលខ្លួនយល់បាន ។

៦. ធានាថា ជនដែលត្រូវគេជួញដូរ ត្រូវបានការពារពីការធ្វើទុក្ខបុកម្នេញ ការគំរាមកំហែង ឬការបំភិតបំភ័យ ដោយជនជួញដូរមនុស្ស និង អ្នកដែលពាក់ព័ន្ធ។ ដើម្បីឱ្យសំរេចគោលបំណងនេះ អត្តសញ្ញាណរបស់ ជនរងគ្រោះ មិនត្រូវឱ្យលេចលឺ ព្រមទាំងរក្សា និងគោរពភាពសំងាត់ឱ្យបានល្អ ព្រមទាំងត្រូវគិតពីសិទ្ធិរបស់ជនជាប់ចោទដែលត្រូវ ទទួលបានការកាត់ក្តីប្រកបដោយយុត្តិធមិផងដែរ។ ជនត្រូវគេជួញដូរ ត្រូវទទួលបានការជូនដំណឹងជាមុន ពីការលំបាក នានា ហើយមិនគួរផ្តល់ពតិមានមិនពិត ឬពតិមានដែលមិនអាចធ្វើបាន ដោយមន្ត្រីអនុវត្តច្បាប់ពីបញ្ហានេះ ។

៧. ធានាថាជនដែលត្រូវគេជួញដូរ ត្រូវបានជួយឱ្យត្រលប់ទៅប្រទេសកំណើតវិញ ដោយពិចារណាពីសុវត្ថភាព និងអនុវត្តទៅតាមគោលការណ៍ស្ម័គ្រចិត្ត ហើយអាចសុំសិទ្ធិជ្រកកោននៅក្នុងប្រទេសកំពុងស្នាក់អាស្រ័យ ឬទៅរស់នៅក្នុង ប្រទេសទី៣ ដោយអនុលោមតាមគោលការណ៍ពិសេស (ដូចជា ការការពារពី ការសងសឹក ឬជននេះពិតជាត្រូវគេជួញដូរម្តងទៀតមិនខានឡើយ)។

៨. សហការជាដៃគូរជាមួយអង្គការមិនមែនរដ្ឋភិបាល រដ្ឋគួរធានាថាជនត្រូវគេជួញដូរដែលបានត្រលប់ទៅកាន់ប្រទេស កំណើតរបស់គេវិញ ត្រូវតែទទួលជំនួយ និងកិច្ចគាំទ្រជាចាំបាច់ ដើម្បីធានាឱ្យពួកគេមានសុខភាព ។ រដ្ឋត្រូវធានាជួយសំរួលដំណើរការធ្វើសមាហរណកម្ម និងការពារពួកគេមិនឱ្យ ទទួលរងនូវការជួញដូរម្តងទៀត ។ វិធានការនានា ត្រូវធានាឱ្យបាន សមស្របនូវ ការថែរក្សាសុខភាព ផ្លូវកាយ ផ្លូវចិត្ត លំនៅដ្ឋាន ការអប់រំ និង ការកការងារឱ្យធ្វើ ចំពោះជនដែលបានត្រលប់ទៅមាតុភូមិវិញ ។

## គោលការណ៍ណែនាំទី៧: ការទប់ស្កាត់អំពើជួញដូរមនុស្ស

**យុទ្ធសាស្ត្រទាំងអស់ដែលមានគោលដៅទប់ស្កាត់អំពើជួញដូរមនុស្ស គួរពិចារណាទៅលើ សេចក្តីតំរូវការ និងមូលហេតុ នៃការជួញដូរមនុស្ស ។ រដ្ឋនានា និងអង្គការរដ្ឋនានា គួរយកចិត្តទុកដាក់លើកត្តានានាដែលធ្វើឱ្យមានការកើនឡើង នូវភាពងាយរងគ្រោះដោយសារអំពើជួញដូរមនុស្ស រួមមាន ភាពមិនស្មើគ្នា ភាពក្រីក្រ និងទំរង់ទាំងអស់នៃការរើសអើង និង ការប៉ះពាល់លើសិទ្ធនានា ។ យុទ្ធសាស្ត្រទប់ស្កាត់ប្រកបដោយប្រសិទ្ធភាព គួរឈរលើមូលដ្ឋាននៃបទពិសោធន៍ និងពត៌មានជាក់លាក់ដែលមាន ។**

**ដោយមានដៃគូរជាមួយអង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ហើយបើអាចធ្វើទៅបាន ដោយប្រើប្រាស់គោលនយោបាយ និងកម្មវិធីកិច្ចសហប្រតិបត្តិការដែលបានបង្កើតឡើង រដ្ឋទាំងអស់ គួរពិចារណា :**

១. វិភាគលើកត្តានានា ដែលនាំឱ្យមានសេចក្តីតំរូវការនៃសេវាពាណិជ្ជកម្មកេងប្រវ័ញ្ចផ្លូវភេទ និងការកេងប្រវ័ញ្ចលើកំលាំងពលកម្ម និងចាត់វិធានការឱ្យបានខ្លាំងខាងផ្នែកច្បាប់ គោលនយោបាយ និងមធ្យោបាយផ្សេងៗទៀត ដើម្បីដោះស្រាយលើបញ្ហាទាំងនេះ ។

២. បង្កើតកម្មវិធីនានា ដែលផ្តល់ជំរើសរបៀបរស់នៅ រួមមាន ការអប់រំជាមូលដ្ឋាន ការបណ្តុះបណ្តាលជំនាញ និងអក្ខរកម្ម ជាពិសេសសំរាប់ស្ត្រី និងក្រុមដែលងាយរងគ្រោះតាមរយៈប្រពៃណី ។

៣. ជំរុញកុមារឱ្យទទួលបានឱកាសក្នុងការសិក្សា និងបង្កើនកំរិតចូលរៀន ជាពិសេស កុមារី ។

៤. ធានាថា ជនទេសន្តប្រវេស្តសំខាន់ៗ ជាពិសេសស្ត្រី ត្រូវបានទទួលព័តមានត្រឹមត្រូវពីគ្រោះថ្នាក់នៃចំណាកស្រុក ( ដូចជា ការកេងប្រវ័ញ្ច បំណុលដោយមានលក្ខខណ្ឌបង្ខំ និងបញ្ហាសុខភាព និងសុវត្ថភាព រួមមានការចម្លងជំងឺ ហ៊ីវ ឬ អេដស៍ ) ព្រមទាំងមធ្យោបាយនៃចំណាកស្រុកស្របច្បាប់ និងមិនមានការកេងប្រវ័ញ្ច ។

៥. បង្កើតយុទ្ធនាការជាសាធារណៈ ដើម្បីបង្កើនការយល់ដឹងពីគ្រោះថ្នាក់នៃអំពើជួញដូរមនុស្ស ។ យុទ្ធនាការនេះ គួរផ្តល់ព័តមានឱ្យមានការយល់ដឹងពី ភាពស្មុគស្មាញដែលពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស និងមូលហេតុនានា ដែលជនទាំងឡាយសំរេចធ្វើការចំណាកស្រុកប្រកបដោយគ្រោះថ្នាក់នោះ ។

៦. ពិនិត្យ និងកែតំរូវ គោលនយោបាយនានាដែលអាចជំរុញឱ្យពលរដ្ឋធ្វើចំណាកស្រុកដើម្បីរកការងារធ្វើដោយខុសប្រក្រតី និងមានលក្ខណៈងាយរងគ្រោះ ។ ដំនើរការនេះ គួររួមមាន ការពិនិត្យលើផលប៉ះពាល់លើស្ត្រីនៃការរារាំង និងឬ ការរើសអើងខាងផ្នែកជាតិសាសន៍ ទ្រព្យសម្បត្តិ អន្តោប្រវេសន្ត ទេសន្តប្រវេសន្ត និងច្បាប់ការងារ សំរាប់ជនទេសន្តប្រវេសន្ត ។

៧. ពិនិត្យលើមធ្យោបាយនានាដើម្បីបង្កើនលទ្ធភាពការងារទេសន្តប្រវេស្ត ប្រកបដោយស្របច្បាប់,អត្ថប្រយោជន៍, និង មិនមានការកេងប្រវ័ញ្ច ។ ការបង្កើនការងារទេសន្តប្រវេស្តដោយរដ្ឋ គួរឈរលើមូលដ្ឋាននៃយន្តការ ប្រកបដោយការគ្រប់គ្រង និងការត្រួតពិនិត្យ ដើម្បីការពារសិទ្ធរបស់កម្មករទេសន្តប្រវេស្ត ។

៨. ពង្រឹងសមត្ថភាពដល់ភ្នាក់ងារអនុវត្តច្បាប់ ដើម្បីចាប់ខ្លួន និងចោទប្រកាន់លើអ្នកពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស គឺជាមធ្យោបាយទប់ស្កាត់មួយ ។ ការពង្រឹងសមត្ថភាពនេះ គួរធានាផងដែរថា ភ្នាក់ងារអនុវត្តច្បាប់ អនុវត្តទៅតាមកាតព្វកិច្ចនៃច្បាប់របស់ខ្លួន ។

៩. អនុម័តវិធានការនានា ដើម្បីកាត់បន្ថយភាពងាយរងគ្រោះថ្នាក់ ដោយធានាថា ឯកសារតាមផ្លូវច្បាប់សមស្រប ដូចជា លិខិតកំណើត អត្តសញ្ញាណប័ណ្ណសញ្ជាតិ លិខិតអាពាហ៍ពិពាហ៍ ត្រូវបានផ្តល់ឱ្យ ហើយប្រជាពលរដ្ឋទាំងអស់ត្រូវមានលិខិតទាំងអស់នេះ ។

## គោលការណ៍ណែនាំទី៤ : វិធានការពិសេសសំរាប់ការពារ និងគាំទ្រដល់កុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស

កុមាររងគ្រោះដោយសារអំពើជួញដូរមនុស្សដែលទទួលរងវិបត្តិផ្លូវកាយ និងផ្លូវចិត្ត និងការកើនឡើងភាពងាយរងគ្រោះក្នុងការកេងប្រវ័ញ្ច គឺតំរូវថា កុមារទាំងអស់នោះត្រូវបែងចែកពីជនរងគ្រោះដោយសារអំពើជួញដូរមនុស្សពេញវ័យ ខាងផ្នែក ច្បាប់ គោលនយោបាយ កម្មវិធី និងការអន្តរាគមន៍ ។ អត្ថប្រយោជន៍ចំបងរបស់កុមារត្រូវយកចិត្តទុកដាក់ជាចំបង នៅក្នុងសកម្មភាពទាំងអស់ពាក់ព័ន្ធទៅនឹងកុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស ទោះបីសកម្មភាពទាំងនោះធ្វើឡើងដោយស្ថាប័នសុខមាលភាពសង្គមរបស់រដ្ឋ ឬ ឯកជន, តុលាការ, ស្ថាប័នរដ្ឋបាលសាធារណៈ ឬ ស្ថាប័ននីតិបញ្ញត្តិ នោះទេ ។ កុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស គួរទទួលបានកិច្ចគាំទ្រ និងការពារសមស្រប ហើយគួរយកចិត្តទុកដាក់ទៅលើសិទ្ធ និងសេចក្តីត្រូវការពិសេសរបស់ពួកគេ ។

**រដ្ឋ បើអាចមាន អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល គួរតែពិចារណាលើ វិធានការដែលមាននៅក្នុង គោលការណ៍ណែនាំទី៦ :**

១. ធានាថា និយមន័យនៃអំពើជួញដូរកុមារ ទាំងនៅក្នុងច្បាប់ និងគោលនយោបាយ គឺត្រូវចែងពីសេចក្តីត្រូវការរបស់កុមារ ឱ្យមានការថែរក្សា និងយកចិត្តទុកដាក់ជាពិសេស រួមមាន កិច្ចការពារខាងផ្នែកផ្លូវច្បាប់ឱ្យបានសមស្រប ។ ជាពិសេស និងយោងតាមពិធីសារប៉ាលឡឺម៉ូ ភស្តុតាងនៃការបោកប្រាស់ ការបង្ខំ......មិនគួរជាធាតុផ្សំនៃនិយមន័យ អំពើជួញដូរមនុស្ស បើអំពើជួញដូរមនុស្ស មានការពាក់ព័ន្ធទៅនឹងកុមារ ។

២. ធានាឱ្យមាននីតិវិធីនៅក្នុងការកំណត់អត្តសញ្ញាណឱ្យបានឆាប់របស់កុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស ។

៣. ធានាថា កុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស មិនត្រូវស្ថិតនៅក្រោមនីតិវិធីព្រហ្មទណ្ឌ ឬ ការផ្តន្ទាទោសឡើយ ចំពោះបទល្មើសនានាដែលពាក់ព័ន្ធទៅនឹងស្ថានភាពរបស់ខ្លួនជាមនុស្សដែលត្រូវគេជួញដូរ ។

៤. នៅក្នុងករណីកុមារមិនត្រូវបាននាំមកដោយសាច់ញាតិ ឬអាណាព្យាបាលនោះទេ ត្រូវចាត់វិធានការជាជំហាន១ ដើម្បីកំណត់អត្តសញ្ញាណ និងកំណត់ទីតាំងសមាជិកគ្រួសារ ។ បន្ទាប់ពីការវាយតំលៃពីភាពគ្រោះថ្នាក់ដែលអាចកើតមានឡើង (ហានិភ័យ) និងការពិគ្រោះយោបល់ជាមួយកុមាររួចហើយ ត្រូវចាត់វិធានការដើម្បីសំរបសំរួលឱ្យមានការជួបជុំឡើងវិញរវាងកុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស និងក្រុមគ្រួសាររបស់ពួកគេ ក្នុងករណីដែលយល់ឃើញថា ការធ្វើបែបនេះ ពិតជានឹងផ្តល់អត្ថប្រយោជន៍ធំបំផុតដល់កុមារ ។

៥. នៅក្នុងស្ថានភាពនៃការវិលត្រលប់ប្រកបដោយសុវត្ថភាពរបស់កុមារទៅក្នុងក្រុមគ្រួសាររបស់ខ្លួនវិញ មិនអាចធ្វើទៅបាន ឬ ការវិលត្រលប់ទៅជួបជុំក្រុមគ្រួសារវិញ គឺមិនបានផ្តល់អត្ថប្រយោជន៍ល្អបំផុតដល់កុមារ ដូចនេះ តំរូវឱ្យមានការរៀបចំថែរក្សាសមស្របដោយគោរពសិទ្ធ និងសេចក្តីថ្លៃថ្នូររបស់កុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស ។

៦. នៅក្នុងស្ថានភាពទាំងពីរនៃការបញ្ជូនកុមារឱ្យវិលត្រលប់ជួបជុំគ្រួសារវិញ ដែលបានចែងនៅក្នុងកថាខណ្ឌទាំងពីរខាងលើនោះ រដ្ឋត្រូវធានាថា កុមារដែលអាចបញ្ចេញទស្សនៈយោបល់របស់ខ្លួនបាន ត្រូវទទួលបានសិទ្ធិក្នុងការបញ្ចេញមតិយោបល់ដោយសេរី លើរាល់បញ្ហាទាំងអស់ដែលមានការពាក់ព័ន្ធទៅនឹងកុមារនោះ ជាពិសេសពាក់ព័ន្ធទៅនឹងសេចក្តីសំរេចអំពីលទ្ធភាពក្នុងការវិលត្រលប់ទៅជួបជុំក្រុមគ្រួសារវិញ ។ មតិយោបល់របស់កុមារត្រូវធ្វើការថ្លឹងថ្លែងដោយយោងទៅតាមអាយុ និងភាពចាស់ចិត្តចាស់គំនិតរបស់គេផង ។

៧. អនុម័តគោលនយោបាយ និងកម្មវិធីជាលក្ខណៈឯកទេស ដើម្បីការពារ និងគាំទ្រដល់កុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស ។ កុមារគួរទទួលបានកិច្ចគាំពារខាងផ្នែកផ្លូវកាយ ផ្លូវចិត្ត ផ្នែកច្បាប់ ការអប់រំ ការស្នាក់នៅ និងការថែទាំសុខភាព ។

៨. អនុម័តវិធានការចាំបាច់ ដើម្បីការពារសិទ្ធ និងអត្ថប្រយោជន៍របស់កុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស រាល់ដំណាក់កាលទាំងអស់នៅក្នុងនិតិវិធីព្រហ្មទណ្ឌប្រឆាំងជនសង្ស័យ និងនៅក្នុងរយៈពេលនីតិវិធីទាមទារសំណងជំងឺចិត្ត ។

៩. ក្នុងករណីសមស្រប ការពារជីវិតឯកជន និងសេចក្តីថ្លៃថ្នូររបស់កុមាររងគ្រោះ និងចាត់វិធានការនានាដើម្បីកុំឱ្យមានលេចលឺព័តមានពីអត្តសញ្ញាណកុមាររងគ្រោះ ។

១០. ចាត់វិធានការ ដើម្បីធានាឱ្យមានការបណ្តុះបណ្តាលគ្រប់គ្រាន់និងសមស្រប ជាពិសេស ការបណ្តុះបណ្តាលខាងផ្នែកច្បាប់ និងចិត្តសាស្ត្រ ដល់អ្នកធ្វើការជាមួយកុមាររងគ្រោះដោយសារអំពើជួញដូរមនុស្ស ។

## គោលការណ៍ណែនាំទី៩ : សិទ្ធិទទួលបានសំណងជំងឺចិត្ត

**ជនដែលត្រូវគេជួញដូរ គឺជាជនរងគ្រោះដោយការរំលោភខាងសិទ្ធិមនុស្ស ត្រូវមានសិទ្ធិស្របច្បាប់អន្តជាតិ ដើម្បីទទួលសំណងជំងឺចិត្ត ត្រឹមត្រូវ និងសមស្រប។ ជាញឹកញាយ សិទ្ធិនេះ គឺមិនផ្តល់ឱ្យបានដល់ ជនដែលត្រូវគេជួញដូរ ឡើយ ដោយហេតុថា ពួកគេខ្វះពត៌មានពី ឱកាសទទួលបានសំណងជំងឺចិត្ត ពីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច ។ ដើម្បីជំនះលើឧបសគ្គនេះ ជំនួយខាងផ្នែកច្បាប់ និងជំនួយខាងផ្នែកឯកសារដទៃទៀត គួរតែផ្តល់ដល់ ជនដែលត្រូវគេជួញដូរ ដើម្បីឱ្យពួកគេទទួលបាន សិទ្ធិក្នុងការទទួលបានសំណងជំងឺចិត្តត្រឹមត្រូវ និងសមស្រប ។**

រដ្ឋ បើអាចមាន អង្គការស្ថាប័នរបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល គួរពិចារណាលើ វិធានការនានាដូចខាងក្រោម:

១. ធានាថា ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស មានសិទ្ធិទទួលបានសំណងជំងឺចិត្ត ប្រកបដោយយុត្តិធម៌ និងពេញលេញ រួមបញ្ចូលទាំង សិទ្ធិទទួលបានការធ្វើនីតិសម្បទា បើអាចធ្វើទៅបាន ។ សំណងជំងឺចិត្តទាំងនេះ អាចជាប្រភេទ ព្រហ្មទណ្ឌ រដ្ឋប្បវេណីយ ឬរដ្ឋបាល ។

២. ផ្តល់ពត៌មាន ព្រមទាំងជំនួយខាងផ្នែកច្បាប់ និងខាងផ្នែកផ្សេងៗទៀត ដើម្បីធ្វើឱ្យ ជនដែលត្រូវគេជួញដូរ អាចទទួលបានសំណងជំងឺចិត្ត ។ នីតិវិធីដើម្បីឱ្យទទួលបានសំណងជំងឺចិត្ត គឺត្រូវបានពន្យល់យ៉ាងច្បាស់ជាភាសាដែលជនត្រូវគេជួញដូរ អាចយល់បាន ។

៣. ការរៀបចំឱ្យជនរងគ្រោះទទួលបានសុវត្ថភាព នៅក្នុងប្រទេសដែលសំណងជំងឺចិត្ត កំពុងដំណើរការរឿងក្តីព្រហ្មទណ្ឌរដ្ឋប្បវេណីយ ឬរដ្ឋបាល ។

## គោលការណ៍ណែនាំ ទី១០ : កាតព្វកិច្ចរបស់ភ្នាក់ងាររក្សាសន្តិភាព នគរបាល និងបុគ្គលិកមនុស្សធម៌ និង មន្ត្រីការទូត

ការពាក់ព័ន្ធដោយផ្ទាល់ និងដោយមិនផ្ទាល់ របស់បុគ្គលិកថែរក្សាសន្តិភាព អ្នកកសាងសន្តិភាព នគរបាល បុគ្គលិកមនុស្សធម៌ និងមន្ត្រីការទូត នៅក្នុងអំពើជួញដូរមនុស្ស គឺ ជាបញ្ហាព្រួយបារម្ភធ្ងន់ធ្ងរបំផុត ។ រដ្ឋ អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល គឺត្រូវទទួលខុសត្រូវចាត់វិធានការចំពោះអ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន។ ដូចនេះហើយ រដ្ឋ អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវមានកាតព្វកិច្ចចាត់វិធានការឱ្យមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់កុំឱ្យប្រជាពលរដ្ឋរបស់ខ្លួន ឬ បុគ្គលិករបស់ខ្លួន ប្រព្រឹត្តិអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចដែលមានការពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ។ រដ្ឋ អង្គការអន្តររដ្ឋាភិបាល និង អង្គការមិនមែនរដ្ឋាភិបាល តំរូវឱ្យធ្វើការស៊ើបអង្កេតផងដែរ លើពាក្យបណ្តឹងក្នុងរឿងក្តីជួញដូរមនុស្សទាំងអស់ និងការកេងប្រវ័ញ្ចដែលពាក់ព័ន្ធ និងចែងទោសបញ្ញត្តិ និងអនុវត្តការផ្តន្ទាទោសឱ្យបានសមស្រប ទៅលើបុគ្គលិកដែលរកឃើញថាមានការពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ។

**រដ្ឋ និងបើអាចមាន អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា គួរពិចារណា :**

១. ធានាឱ្យមានកម្មវិធីបណ្តុះបណ្តាលមុន និងក្រោយការដាក់ពង្រាយបុគ្គលិកថែរក្សាសន្តិភាព បុគ្គលិកកសាង-សន្តិភាព នគរបាល បុគ្គលិកមនុស្សធម៌ និងមន្ត្រីការទូត ដើម្បីដោះស្រាយឱ្យបានសមស្រប លើបញ្ហាជួញដូរមនុស្ស និងធ្វើការកំណត់បទដ្ឋានខាងចរិយាមាយាទ ឱ្យពួកគេអនុវត្តតាម ។ ការបណ្តុះបណ្តាលនេះ គួររៀបចំឡើងទៅតាមក្របខណ្ឌសិទ្ធមនុស្ស និង បង្រៀនដោយអ្នកបណ្តុះបណ្តាលដែលមានបទពិសោធន៍សមស្រប ។

២. ធានាថា នីតិវិធីនៃការជ្រើសរើស ការតែងតាំង និងការផ្ទេរបុគ្គលិក (រួមមាន អ្នកម៉ៅការឯកជន និងម៉ៅការជួលបន្ត) ត្រូវធ្វើឡើងឱ្យបានតឹងរឹង និង ប្រកបដោយតម្លាភាព ។

៣. ធានាថា បុគ្គលិកបំរើការងារនៅក្នុងក្របខណ្ឌបេសកកម្មជា បុគ្គលិកថែរក្សាសន្តិភាព បុគ្គលិកកសាងសន្តិភាព នគរបាល បុគ្គលិកមនុស្សធម៌ និងមន្ត្រីការទូត មិនត្រូវប្រព្រឹត្តិអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពាក់ព័ន្ធនានា ឬ ការប្រើប្រាស់សេវារបស់មនុស្សដែលមានមូលហេតុសមស្របដោយសង្ស័យថា មនុស្សទាំងអស់នោះ គឺត្រូវបានគេជួញដូរ ។ កាតព្វកិច្ចនេះ គ្របដណ្តប់ផងដែរទៅលើអំពើសមគំនិតនៅក្នុងអំពើជួញដូរមនុស្ស

តាមរយៈអំពើពុករលួយ ឬការសំរបសំរួលជាមួយជនណាមួយ ឬក្រុមជនណាណាមួយ ដែលមានហេតុផលគួរឱ្យសង្ស័យថាបានប្រព្រឹត្តិអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចដែលពាក់ព័ន្ធ ។

៤. រៀបចំ និងអនុម័តបទបញ្ជា និងក្រមសីលធមិជាក់លាក់ ដោយកំណត់បទដ្ឋានខាងចរិយាមាយាទ និងផលវិបាកនៃការមិនអនុវត្តតាមបទដ្ឋាននោះ ។

៥. តំរូវឱ្យ បុគ្គលិកបំរើការងារនៅក្នុងក្របខណ្ឌបេសកកម្ម ជាបុគ្គលិកថែរក្សាសន្តិភាព បុគ្គលិកកសាងសន្តិភាព នគរបាល បុគ្គលិកមនុស្សធមិ និងមន្ត្រីការទូត រាយការណ៍រាល់ករណីអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចពាក់ព័ន្ធនានា ដែលខ្លួនបានដឹងនោះ ។

៦. បង្កើតយន្តការស៊ើបអង្កេតជាលក្ខណៈប្រព័ន្ធ រាល់ពាក្យបណ្តឹងនៅក្នុងរឿងក្តីជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា នៅក្នុងរឿងក្តីជួញដូរមនុស្ស ពាក់ព័ន្ធទៅនឹងបុគ្គលិកបំរើការងារនៅក្នុងក្របខណ្ឌបេសកកម្ម ជាបុគ្គលិកថែរក្សាសន្តិភាព បុគ្គលិកកសាងសន្តិភាព នគរបាល បុគ្គលិកមនុស្សធមិ និងមន្ត្រីការទូត ។

៧. បុគ្គលិកនោះត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌ រដ្ឋប្បវេណី និងរដ្ឋបានឱ្យបានស៊ីសង្វាក់ និងសមស្របទៅនឹងអំពើប្រព្រឹត្តិ ឬអំពើសមគំនិត នៅក្នុងរឿងក្តីជួញដូរមនុស្ស និង ការកេងប្រវ័ញ្ចពាក់ព័ន្ធនានា ។ នៅក្នុងករណីសមស្រប អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវអនុវត្តទោសវិន័យដល់បុគ្គលិករបស់ខ្លួន ដែលរកឃើញថា មានការពាក់ព័ន្ធនៅក្នុងរឿងក្តីជួញដូរមនុស្ស និង ការកេងប្រវ័ញ្ចពាក់ព័ន្ធនានា ។ ទោសវិន័យនេះ គឺជាការបន្ថែមទៅនឹង និងជាទោសវិន័យផ្សេងពី ការផ្តន្ទាទោសព្រហ្មទណ្ឌ ឬការផ្តន្ទាទោសផ្សេងទៀតសំរេចឡើងដោយរដ្ឋ ។ បុព្វសិទ្ធ ឬ អភ័យឯកសិទ្ធរបស់បុគ្គលិកណាមួយនោះ មិនត្រូវយកមកប្រើប្រាស់នោះទេ ដើម្បីកុំឱ្យជននោះរួចផុតពីការផ្តន្ទាទោសបទឧក្រិដ្ឋធ្ងន់ធ្ងរ ដូចជាបទល្មើសជួញដូរមនុស្ស និង បទល្មើសកេងប្រវ័ញ្ចពាក់ព័ន្ធនានា ។

## គោលការណ៍ណែនាំ ទី១១ : អនុសាសន៍ ជាគោលការណ៍ទូទៅ និងជាគោលការណ៍ណែនាំបានចែងដូចខាងក្រោយស្តីពី ការសំរបសំរួល និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋនិងរដ្ឋ និងរវាងតំបន់នានា :

ការជួញដូរមនុស្ស គឺជាបាតុភូតតំបន់ និងពិភពលោកទាំងមូល ជានិច្ចកាល គឺមិនអាច ដោះស្រាយបានប្រកបដោយប្រសិទ្ធិភាព នៅថ្នាក់ជាតិបានឡើយ : ជួនកាល ការពង្រឹងលើការឆ្លើយតបថ្នាក់ជាតិ អាចធ្វើឱ្យកិច្ចប្រតិបត្តិការរបស់ជនជួញដូរមនុស្សផ្លាស់ទៅរដ្ឋផ្សេងៗទៀតក្នុងតំបន់។ ដូច្នេះហើយ កិច្ចសហប្រតិបត្តិថ្នាក់

អន្តរជាតិជាពហុភាគី និងទ្វេភាគី អាចដើរតួនាទីដ៏សំខាន់ក្នុងការប្រឆាំងសកម្មភាព ជួញដូរមនុស្សបាន។ ជាពិសេស កិច្ចសហប្រតិបត្តិការបែបនេះ គឺជាបញ្ហាដ៏សំខាន់ រវាងប្រទេសនានា ដែលមានការពាក់ព័ន្ធ នៅក្នុងដំណាក់កាលផ្សេងៗ ជាច្រើន នៅក្នុងវដ្ត (ការកកើតឡើងវិញ) នៃ អំពើជួញដូរមនុស្ស។

**រដ្ឋ និងបើអាចមាន អង្គការអន្តររដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា គួរពិចារណា:**

១. អនុម័តលើកិច្ចព្រមព្រៀងជាទ្វេភាគី ក្នុងគោលបំណងប្រឆាំងនឹងការជួញដូរមនុស្ស ការពារនូវសិទ្ធិ និង សេចក្តីថ្លៃថ្នូរ របស់ជនដែលត្រូវគេជួញដូរ ព្រមទាំងលើកស្ទួយ សុខមាលភាពរបស់ពួកគេ។

២. ឈរលើមូលដ្ឋានជាទ្វេភាគី ឬតាមរយៈអង្គការពហុភាគី ផ្តល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុដល់រដ្ឋផ្សេងៗ ឬផ្នែកណាមួយរបស់សង្គមស៊ីវិលដែលប្រតិបត្តិការងារ ក្នុងទិសដៅលើកកំពស់ និងបង្កើន កិច្ចប្រតិបត្តិការអនុវត្តន៍ យុទ្ធសាស្ត្រនានាដែលផ្អែកលើ សិទ្ធិមនុស្សជាមូលដ្ឋាន ដើម្បីប្រឆាំងអំពើជួញដូរមនុស្ស។

៣. បង្កើតឱ្យមានកិច្ចព្រមព្រៀងថ្នាក់តំបន់ និងអនុតំបន់ស្តីពីការជួញដូរមនុស្ស ដោយប្រើប្រាស់ពិធីសារប៉ាលឺម៉ូ និង បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនានា សំរាប់ជាខ្នាត និងក្របខណ្ឌការងារ។

៤. អនុម័តសិទ្ធិសញ្ញាស្តីពីពលកម្មទេសន្តរប្រវេសន្ត ដែលអាចមានបទបញ្ញត្តិ ស្តីពីស្តង់ដា អប្បបរិមាសំរាប់ការងារ គំរូកិច្ចសន្យា វិធីសាស្ត្រសំរាប់ផ្ញើមាតុភូមិនិវត្ត.... ឱ្យស្របទៅនឹងបទដ្ឋានអន្តរជាតិជាធរមាន។ រដ្ឋត្រូវបានលើកទឹកចិត្ត ឱ្យអនុវត្ត កិច្ចព្រមព្រៀងទាំងនេះឱ្យបានតឹងរឹង ដើម្បីជួយលុបបំបាត់ការជួញដូរមនុស្ស និង ការកេងប្រវ័ញ្ចពាក់ព័ន្ធ។

៥. បង្កើតឱ្យមានការរៀបចំ កិច្ចសហប្រតិបត្តិការ ដើម្បីសំរបសំរួលឱ្យមានការកំណត់ជនណាមួយជាជនរងគ្រោះ ដោយសារអំពើជួញដូរឱ្យបានឆាប់ រួមទាំង ការចែករំលែក និងការផ្លាស់ប្តូរពត៌មាន ដែលទាក់ទងទៅនឹងសញ្ជាតិ និងសិទ្ធិស្របច្បាប់ ក្នុងការរស់នៅរបស់គេ។

៦. បង្កើតឱ្យមានយន្តការផ្សេងៗ ដើម្បីសំរួលដល់ការប្តូរពត៌មានដែលទាក់ទងទៅនឹង ជនជួញដូរមនុស្ស និងវិធីសាស្ត្រ ប្រតិបត្តិការជួញដូររបស់ ជនជួញដូរមនុស្ស។

៧. បង្កើតឱ្យមាននិតិវិធី និងពិធីសារសំរាប់ការស៊ើបអង្កេតរួមគ្នាដែលផ្តួចផ្តើមឡើង ដោយប៉ូលីសនៃរដ្ឋផ្សេងៗគ្នា ។ ដោយទទួលស្គាល់នូវតំលៃនៃការទំនាក់ទំនងដោយផ្ទាល់ បទបញ្ញាតិទាំងនោះ គួរតែផ្តល់ចំពោះការទំនាក់ទំនង ដោយផ្ទាល់ សំរាប់សំណើរសុំជំនួយរវាងអាជ្ញាធរមានសមត្ថកិច្ចនៅថ្នាក់មូលដ្ឋាន ដើម្បីធានាថា សំណើរទាំងនេះត្រូវបាន ដោះស្រាយជាបន្ទាន់ និងជំរុញបង្កើតឱ្យមានទំនាក់ទំនងសហប្រតិបត្តិការ នៅថ្នាក់មូលដ្ឋាន។

៨. ធានាឱ្យមានកិច្ចសហប្រតិបត្តិការខាងវិស័យតុលាការ រវាងរដ្ឋនិងរដ្ឋ នៅក្នុង ការស៊ើបអង្កេត និងដំណើរការរបស់តុលាការដែលទាក់ទងទៅនឹងការជួញដូរមនុស្ស និង បទល្មើសដែលពាក់ព័ន្ធ ជាពិសេស តាមរយៈវិធីសាស្ត្រចោទប្រកាន់ដូចគ្នា និងការស៊ើបអង្កេតរួមគ្នា។ កិច្ចសហប្រតិបត្តិការនេះ គួរបញ្ចូលនូវកិច្ចគាំទ្រ : កំណត់ និងធ្វើការសំភាសន៍សាក្សីឱ្យបានត្រឹមត្រូវ ដើម្បីធានាសុវត្ថិភាពរបស់ពួកគេ, ធ្វើការកំណត់ ការទទួលបាន និងការថែរក្សាភស្តុតាង, ផ្តល់ឯកសារច្បាប់ចាំបាច់ ដើម្បីទទួលបានភស្តុតាង និងសាក្សី, និងការអនុវត្តសាលក្រម។

៩. ធានាថា សំណើរសុំបត្យាប័នចំពោះបទល្មើសនានា ដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ត្រូវបានដោះស្រាយដោយអាជ្ញាធរនៃរដ្ឋទទួលសំណើរ ដោយគ្មានការពន្យាពេល។

១០. បង្កើតយន្តការសហប្រតិបត្តិការ ក្នុងការរឹបអូសវត្ថុតាងនានាដែលពាក់ព័ន្ធនឹងការជួញដូរមនុស្ស។ កិច្ចសហ-ប្រតិបត្តិការនេះ គួរតែបញ្ចូលនូវបទបញ្ញត្តិនៃជំនួយ សំរាប់ការបញ្ជាក់នូវអត្តសញ្ញាណ ការស្វែងរកឱ្យឃើញ ការឃាត់ទុក និងរឹបអូសយក ទ្រព្យសម្បត្តិដែលបានមកពីការជួញដូរ និងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច។

១១. ផ្លាស់ប្តូរពត៌មាន និងបទពិសោធន៍ ដែលពាក់ព័ន្ធនឹងការអនុវត្តន៍ជំនួយ, កម្មវិធីមាតុភូមិនិវត្តន៍ និងសមាហរណកម្ម ក្នុងគោលបំណងដើម្បីធ្វើយ៉ាងណាឱ្យធានាបានផលប្រយោជន៍ជាអតិបរិមា ដល់ជនរងគ្រោះប្រកបដោយប្រសិទ្ធិភាពខ្ពស់។

១២. លើកទឹកចិត្ត និងសំរបសំរួលកិច្ចសហប្រតិបត្តិការ រវាងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដទៃទៀត នៅក្នុងប្រទេសប្រភព ប្រទេសឆ្លងកាត់ និងប្រទេសគោលដៅ នៃការជួញដូរមនុស្ស។ វិធីនេះមានសារៈសំខាន់ជាពិសេស ដើម្បីធានាការគាំទ្រ និងការផ្តល់ជំនួយគាំពារដល់ជនដែលត្រូវគេជួញដូរ ដែលបានធ្វើមាតុភូមិនិវត្តន៍។